សេចក្ដីប្រកាសសារព័ត៌មាន៖ សម្រាប់ការចេញផ្សាយបន្ទាន់

# ក្រុមហ៊ុនH&M Group និង អង្គការWWF សាកល្បងដាក់ដំណើរការកម្មវិធីបញ្ញាសប្បនិម្មិត(AI) ដើម្បីជួយកាត់បន្ថយសម្ពាធលើព្រៃឈើធម្មជាតិនៅកម្ពុជា

**ភ្នំពេញថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២២៖** កម្មវិធីថ្មីមួយដែលប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត ឈ្មោះថា "WoodAI" ត្រូវបានដាក់ឱ្យដំណើរការនៅថ្ងៃនេះ ដើម្បីគាំទ្រដល់រោងចក្រកាត់ដេរ និងវិស័យវាយនភ័ណ្ឌ ក្នុងការកាត់បន្ថយសម្ពាធលើព្រៃឈើធម្មជាតិនៅកម្ពុជា។ នេះជាកិច្ចសហការដ៏ប្រសើរមួយក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាដោយភាពច្នៃប្រឌិតរវាងក្រុមហ៊ុនH&M Group និងអង្គការWWF នៅកម្ពុជា។

**ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថានបានមានប្រសាសន៍ថា៖ «ក្រសួងបរិស្ថានសូមសាទរចំពោះការដាក់ឱ្យប្រើប្រាស់នូវកម្មវិធីបញ្ញាសប្បនិម្មិតសម្រាប់អត្តសញ្ញាណកម្មប្រភេទឈើដែលត្រូវបានបង្កើតឡើងក្រោមភាពជាដៃគូនៃក្រុមហ៊ុន H&M Group និង អង្គការWWF ។ **ឯកឧត្តម** បាននិយាយទៀតថា៖ «យើងសូមកោតសរសើរចំពោះគំនិតផ្ដួចផ្ដើមប្រកបដោយភាពច្នៃប្រឌិតនេះពីសំណាក់ អង្គការWWF និង ក្រុមហ៊ុន H&M Group ហើយសូមស្វាគមន៍ចំពោះការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុន H&M Group ក្នុងការរួមចំណែកដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ និងក្នុងការចូលរួមកាត់បន្ថយសម្ពាធលើព្រៃឈើធម្មជាតិក្នុងខ្សែសង្វាក់ផលិតកម្មរបស់ខ្លួន។»

**ឯកឧត្តមរដ្ឋលេខាធិការ** បានមានប្រសាសន៍បន្ថែមទៀតថា៖ «កម្មវិធី WoodAI គឺជាការរួមចំណែកដ៏សំខាន់មួយក្នុងការដោះស្រាយកត្តាចម្បងៗមួយចំនួនដែលបង្កឱ្យមានការកាប់បំផ្លាញព្រៃឈើ។ ក្រសួងសូមលើកទឹកចិត្តដល់ក្រុមហ៊ុនផលិតសម្លៀកបំពាក់ដទៃៗទៀតអនុវត្តតាមគំរូនេះ និងចូលរួមក្នុងកិច្ចការពារ និងថែរក្សាធនធានព្រៃឈើធម្មជាតិ និងសត្វព្រៃ ដើម្បីជាប្រយោជន៍យូរអង្វែងសម្រាប់មនុស្ស និងធម្មជាតិ។»

**ឯកឧត្តមរដ្ឋលេខាធិការ** ក៏បានអំពាវនាវផងដែរដល់វិស័យឯកជនឲ្យចូលរួមសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ។ ក្រុមហ៊ុនទាំងអស់ក៏ត្រូវបានលើកទឹកចិត្តឱ្យរួមចំណែកអនុវត្តសកម្មភាពនានាតាមលទ្ធភាពដែលខ្លួនធ្វើបានក្នុងការជួយកាត់បន្ថយសម្ពាធលើព្រៃឈើធម្មជាតិ។ រាជរដ្ឋាភិបាលកម្ពុជាគាំទ្រនូវរាល់គំនិតផ្ដួចផ្ដើមដែលគាំទ្រដល់គោលបំណងនេះ គាំទ្រដល់រាល់គម្រោងមេត្រីភាពបរិស្ថាន ដែលលើកកម្ពស់ការអនុវត្ត និងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ និងគាំទ្រដល់ការអភិរក្ស។

កម្មវិធី **WoodAI** អាចកំណត់អត្តសញ្ញាណប្រភេទឈើបានរហ័ស និងអាចគាំទ្រដល់រោងចក្រកាត់ដេរបន្ថែមទៀតក្នុងការដោះស្រាយបញ្ហាកង្វះព័ត៌មានជុំវិញប្រភពជីវម៉ាសដែលពួកគេប្រើប្រាស់។ កម្មវិធីនេះអាចកំណត់អត្តសញ្ញាណប្រភេទឈើដោយប្រើទូរស័ព្ទដៃទំនើប និងកញ្ចក់ម៉ាក្រូ នៅច្រកចូលនៃរោងចក្រដើម្បីជួយរោងចក្រក្នុងការត្រួតពិនិត្យមើលដើម្បីធានាថាប្រភេទឈើដែលពួកគេប្រើសម្រាប់ផលិតជាថាមពលក្នុងខ្សែសង្វាក់ផលិតកម្ម អនុលោមតាមគោលការណ៍របស់ក្រុម

General Information

ហ៊ុន **H&M Group** ពោលគឺឈើដែលបានមកពីចម្ការឈើដាំដូចជាស្វាយ និងស្វាយចន្ទីជាដើម ដែលអាចជួយធានាថា មិនរួមចំណែកដល់ការកាប់បំផ្លាញព្រៃឈើធម្មជាតិនោះឡើយ។

**លោក សេខ ទៀក** នាយកអង្គការWWFកម្ពុជា បានមានប្រសាសន៍ថា៖ «បេសកកម្មរបស់ អង្គការWWF នៅកម្ពុជា គឺអភិរក្សធនធានជីវចម្រុះដ៏សម្បូរបែបនៅក្នុងប្រទេស។ ព្រៃឈើក្នុងប្រទេសកម្ពុជានៅមានសភាពល្អផ្តល់អំណោយផលជាទីជម្រកធម្មជាតិយ៉ាងសំខាន់សម្រាប់ប្រភេទសត្វរងគ្រោះថ្នាក់ជិតផុតពូជជាច្រើនប្រភេទ។ ដូច្នេះហើយ យើងតែងរិះរកនូវវិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗប្រកបដោយការច្នៃប្រឌិត តួយ៉ាងដូចជាកម្មវិធី WoodAI នេះ ព្រោះវាអាចដើរតួនាទីមួយក្នុងការជួយកាត់បន្ថយសម្ពាធមួយចំនួនដែលកំពុងគំរាមកំហែងដល់ព្រៃឈើធម្មជាតិ។»

ការផ្តល់ដល់រោងចក្រនូវបច្ចេកវិទ្យាដែលរួមចំណែកក្នុងការសម្រេចចិត្តបានកាន់តែប្រសើរ គឺជាការបោះជំហានល្អមួយក្នុងការរួមចំណែកកាត់បន្ថយសម្ពាធលើព្រៃឈើ ការពារជីវចម្រុះដ៏សម្បូរបែប និងឆ្លើយតបនឹងបញ្ហាអាកាសធាតុសកល។ វាជាគន្លឹះចាំបាច់ក្នុងវិស័យវាយនភ័ណ្ឌដោយថាមពលដែលគេប្រើក្នុងការផលិតសម្លៀកបំពាក់គឺជាកត្តារួមចំណែកធំបំផុតទៅដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់។ ថាមពលនេះត្រូវបានគេប្រើក្នុងខ្សែសង្វាក់ផលិតកម្មដូចជាការបោកគក់ និងការអ៊ុតសម្លៀកបំពាក់ជាដើម ហើយដែលថាមពលនេះមានប្រភពមកពីធ្យូងថ្ម ឧស្ម័ន និងជីវម៉ាសដូចជាឈើនេះជាដើម។

ការប្រើប្រាស់កម្មវិធី WoodAI ជាផ្នែកមួយក្នុងចំណោមវិធីសាស្ត្រផ្សេងៗទៀតរួមគ្នា វាក្លាយជាធនធានដ៏សំខាន់មួយក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីគ្រប់គ្រងចំការឈើដាំ និងព្រៃឈើធម្មជាតិនៅកម្ពុជាប្រកបដោយការទទួលខុសត្រូវ។ ក្រុមហ៊ុន H&M Group គាំទ្រគម្រោងបែបនេះ ក្នុងគោលបំណងរួមចំណែកក្នុងការការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើឱ្យមានគុណភាពល្អដើម្បីបន្តស្រូបយកឧស្ម័នកាបូនិក។ ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើមានសារៈសំខាន់ណាស់ក្នុងការរក្សាសីតុណ្ហភាពពិភពលោកឱ្យនៅត្រឹម ១.៥ អង្សាសេ ហើយវាក៏មានសារៈសំខាន់ផងដែរសម្រាប់គោលដៅរបស់ក្រុមហ៊ុន H&M Group ក្នុងការសម្រេចបានnet-zeroនៅឆ្នាំ ២០៤០។

លោក Christer Horn af Aminne នាយកក្រុមហ៊ុន H&M Group ប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា៖ «វាពិតរំភើបណាស់សម្រាប់ការសាកល្បងអនុវត្តបច្ចេកវិទ្យាថ្មីនេះនៅកម្ពុជា និងស្វែងរកនូវវិធីសាស្ត្រថ្មីៗដើម្បីគាំទ្រដល់កិច្ចការរបស់យើងជាមួយបណ្តាក្រុមអ្នកផ្គត់ផ្គង់ ដែលអាចជួយកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានលើព្រៃឈើធម្មជាតិរបស់កម្ពុជា។»

-end-

[Link to photos](Link to photos)

Press contacts
WWF Cambodia:
**Miss. Sophearoth Ravy,** Communications Officer, Email: sophearoth.ravy@wwf.org.kh,
H&M Group press inquiries, groupmediarelations@hm.com



**A factory worker using the app on wood**